ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ១៧៤ ព.ណ.ក.ស.មល.សណ

# សេចក្តីសម្រេច
# ស្តីពី
# បែបបទនិងនីតិវិធីនៃការចេញវិញ្ញាបនបត្រជាមុន

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៣ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រកួតប្រជែង
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ ស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

# សម្រេច

**ប្រការ១.-**

សេចក្តីសម្រេចនេះកំណត់អំពីបែបបទនិងនីតិវិធីនៃការចេញវិញ្ញាបនបត្រជាមុនចំពោះការរួមបញ្ចូលគ្នានៃធុរកិច្ច ក្នុងគោលបំណងត្រួតពិនិត្យ និងវាយតម្លៃលើផលប៉ះពាល់ដល់ការប្រកួតប្រជែង។

**ប្រការ២.-**

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះភាគីស្នើសុំរួមបញ្ចូលគ្នានៃធុរកិច្ចដែលមានបំណងស្នើសុំមកគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា «គ.ប.ក.» ដើម្បីចេញវិញ្ញាបនបត្រជាមុន ដោយអនុលោមតាមមាត្រា១៤នៃអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៣ ស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច។

**ប្រការ៣.-**

ភាគីស្នើសុំវិញ្ញាបនបត្រជាមុនត្រូវដាក់ពាក្យស្នើសុំមក **គ.ប.ក.** មុនការបញ្ចប់ផ្នែកសំខាន់ៗនៃការរួមបញ្ចូលគ្នានៃធុរកិច្ច។ ទោះបីការរួមបញ្ចូលគ្នានៃធុរកិច្ចណាមួយមិនមែនជាកម្មវត្ថុនៃការជូនដំណឹងដូចមានចែងក្នុងមាត្រា៤ ឬមាត្រា១៣នៃអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ចក៏ដោយ ភាគីស្នើសុំអាចស្នើសុំវិញ្ញាបនបត្រជាមុនមក **គ.ប.ក.** ស្របតាមការកំណត់ដូចមានចែងក្នុងទម្រង់ពាក្យស្នើសុំវិញ្ញាបនបត្រជាមុននៃការរួមបញ្ចូលគ្នានៃធុរកិច្ច។

ទម្រង់ពាក្យស្នើសុំវិញ្ញាបនបត្រជាមុននៃការរួមបញ្ចូលគ្នានៃធុរកិច្ច ត្រូវកំណត់ដោយ **គ.ប.ក.** និងអាចធ្វើការកែសម្រួលតាមការសម្រេចរបស់ **គ.ប.ក.** ក្នុងករណីចាំបាច់។

អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «ក.ប.ប.» ជាលេខាធិការដ្ឋានរបស់ **គ.ប.ក.** ក្នុងការទទួលពាក្យស្នើសុំវិញ្ញាបនបត្រជាមុន។

**ប្រការ៤.-**

ក្នុងរយៈពេល ៧ (ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានពាក្យស្នើសុំវិញ្ញាបនបត្រជាមុន ដូចមានចែងក្នុងប្រការ៣នៃសេចក្តីសម្រេចនេះ អគ្គនាយកដ្ឋាន **ក.ប.ប.** ត្រូវចេញសេចក្តីជូនដំណឹងដល់ភាគីស្នើសុំវិញ្ញាបនបត្រជាមុន និងបញ្ជាក់នូវឯកសារនិងព័ត៌មានដែលតម្រូវទៅតាមករណីនៃការរួមបញ្ចូលគ្នានៃធុរកិច្ចនីមួយៗ សម្រាប់ការត្រួតពិនិត្យនិងវាយតម្លៃរបស់ **គ.ប.ក.** លើការរួមបញ្ចូលគ្នានៃធុរកិច្ចដែលបានស្នើសុំ។

**ប្រការ៥.-**

**គ.ប.ក.** អាចចេញវិញ្ញាបនបត្រជាមុនបាន ប្រសិនបើក្រោយពីការបញ្ចប់ការត្រួតពិនិត្យ **គ.ប.ក.** មិនមានអំណះអំណាងណាមួយក្នុងការបដិសេធឬចាប់ផ្តើមដំណើរការហាមឃាត់នៃការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំដូចមានចែងក្នុងមាត្រា១១នៃច្បាប់ស្តីពីការប្រកួតប្រជែង។

**ប្រការ៦.-**

ក្នុងករណី **គ.ប.ក.** មានភស្តុតាងដែលអាចបញ្ជាក់ថាឯកសារនិងព័ត៌មានដែលផ្តល់ដោយភាគីស្នើសុំរួមបញ្ចូលគ្នានៃធុរកិច្ច ក្នុងការស្នើសុំវិញ្ញាបនបត្រជាមុនមិនត្រឹមត្រូវនិងគ្រប់គ្រាន់ **គ.ប.ក.** អាចចេញសេចក្តី

ជូនដំណឹងស្តីពីការព្យួរនូវវិញ្ញាបនបត្រជាមុនដែលបានចេញ ដោយភ្ជាប់ជាមួយហេតុផលសមស្របដល់ភាគីស្នើសុំរួមបញ្ចូលគ្នានៃធុរកិច្ច។

អគ្គនាយកដ្ឋាន គ.ប.ប. ត្រូវផ្ញើសេចក្តីជូនដំណឹងនេះទៅភាគីស្នើសុំរួមបញ្ចូលគ្នានៃធុរកិច្ច ដោយផ្អែកលើព័ត៌មានទំនាក់ទំនងដែលបានផ្តល់ក្នុងពាក្យស្នើសុំសម្រាប់ការចេញវិញ្ញាបនបត្រជាមុន។

ភាគីដែលទទួលបានការជូនដំណឹងស្តីពីការព្យួរការចេញវិញ្ញាបនបត្រជាមុន មានរយៈពេល ៧ (ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃដែលទទួលបានសេចក្តីជូនដំណឹង ដើម្បីផ្តល់ភស្តុតាងបន្ថែមមក គ.ប.ក. ដើម្បីបញ្ជាក់ថាព័ត៌មានដែលបានផ្តល់គឺត្រឹមត្រូវនិងគ្រប់គ្រាន់។ ប្រសិនបើ គ.ប.ក. កំណត់ឃើញថាឯកសារនិងព័ត៌មានដែលបានផ្តល់ក្នុងការស្នើសុំការចេញវិញ្ញាបនបត្រជាមុនគឺត្រឹមត្រូវនិងគ្រប់គ្រាន់នោះ គ.ប.ក. ត្រូវចេញសេចក្តីជូនដំណឹងស្តីពីការលុបចោលការព្យួរវិញ្ញាបនបត្រជាមុនដល់ភាគីដែលទទួលបានការជូនដំណឹងស្តីពីការព្យួរវិញ្ញាបនបត្រជាមុន។

ប្រសិនបើភាគីដែលទទួលបានវិញ្ញាបនបត្រជាមុនមិនបានទទួលសេចក្តីជូនដំណឹងស្តីពីការព្យួរការចេញវិញ្ញាបនបត្រជាមុន ដោយផ្អែកលើព័ត៌មានទំនាក់ទំនងដែលបានផ្តល់ ឬមិនអាចបង្ហាញដល់ គ.ប.ក. ថាឯកសារនិងព័ត៌មាន ដែលបានផ្តល់ពីមុនគឺត្រឹមត្រូវនិងគ្រប់គ្រាន់នោះ វិញ្ញាបនបត្រជាមុនដែលបានចេញត្រូវចាត់ទុកជាមោឃៈបន្ទាប់ពីការផុតកំណត់រយៈពេល ៧ (ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ នៃការចេញសេចក្តីជូនដំណឹងស្តីពីការព្យួរការចេញវិញ្ញាបនបត្រជាមុន ដូចមានចែងក្នុងប្រការ៦នៃសេចក្តីសម្រេចនេះ ឬបន្ទាប់ពីការផុតកំណត់នៃថិរវេលាផ្សេងទៀតដែលកំណត់ដោយសេចក្តីសម្រេចរបស់ គ.ប.ក.។

គ.ប.ក. អាចចេញសេចក្តីសម្រេចពន្យាររយៈពេលកំណត់ក្នុងការឆ្លើយតបរបស់ភាគីដែលទទួលបានការជូនដំណឹងស្តីពីការព្យួរការចេញវិញ្ញាបនបត្រជាមុនបានដូចមានចែងក្នុងប្រការ៦នៃសេចក្តីសម្រេចនេះ។

**ប្រការ៧.-**

ក្នុងករណី គ.ប.ក. ចេញវិញ្ញាបនបត្រជាមុនដោយភ្ជាប់ជាមួយលក្ខខណ្ឌ វិញ្ញាបនបត្រជាមុននោះត្រូវចាត់ទុកថាមានសុពលភាព ប្រសិនបើលក្ខខណ្ឌដែលបានកំណត់ដោយ គ.ប.ក. ត្រូវបានបំពេញ ឬមានការសម្រេចផ្សេងទៀតដោយ គ.ប.ក.។

វិញ្ញាបនបត្រជាមុនដែលបានចេញដោយភ្ជាប់ជាមួយលក្ខខណ្ឌត្រូវចាត់ទុកថានៅមានសុពលភាពលុះត្រាតែលក្ខខណ្ឌនោះត្រូវបានបន្តបំពេញ ឬមានការសម្រេចផ្សេងទៀតដោយ គ.ប.ក.។

គ.ប.ក. អាចចេញសេចក្តីសម្រេចកែសម្រួលលើលក្ខខណ្ឌណាមួយដែលមានចែងក្នុងវិញ្ញាបនបត្រជាមុនដែលបានចេញ។

**ប្រការ៨.-**

ដោយអនុលោមតាមមាត្រា១៤នៃអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ចក្នុងរយៈពេល ១ (មួយ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រជាមុន គ.ប.ក. មិនត្រូវបដិសេធ ឬហាមឃាត់

ការរួមបញ្ចូលគ្នានៃធុរកិច្ចដូចមានចែងក្នុងមាត្រា១១នៃច្បាប់ស្តីពីការប្រកួតប្រជែង ដោយផ្អែកលើមូលដ្ឋាននៃឯកសារនិងព័ត៌មាន ដូចគ្នាដែលបានដាក់ស្នើសុំសម្រាប់ជាមូលដ្ឋាននៃការចេញវិញ្ញាបនបត្រជាមុននោះឡើយ។

**ប្រការ៩.-**

ក្នុងករណី គ.ប.ក. កំណត់ឃើញថាមិនអាចធ្វើការចេញវិញ្ញាបនបត្រជាមុនបាន គ.ប.ក. អាចចេញលិខិតបដិសេធស្តីពីការមិនបន្តនីតិវិធីចេញវិញ្ញាបនបត្រជាមុនចំពោះការរួមបញ្ចូលគ្នានៃធុរកិច្ចដែលបានស្នើសុំ ដោយបញ្ជាក់ថា គ.ប.ក. មិនមានចេតនាក្នុងការបដិសេធការរួមបញ្ចូលគ្នានៃធុរកិច្ចដែលបានស្នើសុំក្រោមមាត្រា១១នៃច្បាប់ស្តីពីការប្រកួតប្រជែងនោះទេ។ គ.ប.ក. អាចបដិសេធ ឬហាមឃាត់ការរួមបញ្ចូលគ្នានៃធុរកិច្ចដែលបានស្នើសុំដូចមានចែងក្នុងមាត្រា១១នៃច្បាប់ស្តីពីការប្រកួតប្រជែង ទោះបីជាមិនមានលិខិតបដិសេធស្តីពីការមិនបន្តនីតិវិធីចេញវិញ្ញាបនបត្រជាមុនក៏ដោយ។

ក្នុងករណី គ.ប.ក. ចេញលិខិតបដិសេធស្តីពីការមិនបន្តនីតិវិធីចេញវិញ្ញាបនបត្រជាមុនចំពោះការរួមបញ្ចូលគ្នានៃធុរកិច្ចដែលបានស្នើសុំ ហើយការរួមបញ្ចូលគ្នានៃធុរកិច្ចដែលបានស្នើសុំស្ថិតក្រោមកម្មវត្ថុនៃការជូនដំណឹងជាមុនដូចមានចែងក្នុងអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច នោះការរួមបញ្ចូលគ្នានៃធុរកិច្ចដែលស្នើសុំនោះអាចអនុវត្តតាមនីតិវិធី ដូចមានចែងក្នុងមាត្រា១០នៃអនុក្រឹត្យស្តីពីលក្ខខណ្ឌនិងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច។

**ប្រការ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១.-**

សមាសភាពគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១១កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**និងជាប្រធានគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ